# មេរៀនទី ១១០៖ ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក

## ម៉ាថាយ ៣៖១៣-១៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/AkMOMcAWKzk

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/Af3d5CZT6GI

**គោលបំណង៖** ព្រះយេស៊ូវគឺជាបុត្រារបស់ព្រះ។

**ខគម្ពីរចងចាំ៖** ម៉ាថាយ ៣៖១៧ *"នោះមានឮសំឡេងចេញពីមេឃថា នោះជាកូនស្ងួនភ្ងារបស់អញជាទីពេញចិត្តអញណាស់។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

២. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0

៣. មានសុខសាន្តដូចទន្លេ https://youtu.be/BqKUDsWZq8s

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «គប់ទឹក»**

សម្ភារៈដែលត្រូវការ៖ កៅអីមួយ ប៉េងប៉ោង ( សម្រាប់ច្រកទឹក )

ចំណាំ៖ សូមលេងល្បែងនេះនៅខាងក្រៅ ពីព្រោះកុមារអាចទទឹក

១. សូមពន្យល់កុមារថាថ្ងៃនេះរឿងនៅក្នុងព្រះគម្ពីររបស់យើងនឹងរៀនពីការ ជ្រមុជទឹករបស់ព្រះយេស៊ូវ។



ដូច្នេះមុនពេលដែលយើងរៀនមេរៀននៅថ្ងៃនេះ យើងនឹងលេងល្បែងគប់ទឹកជាមួយគ្នា។

២. ឲ្យប៉េងប៉ោងទៅកុមារម្នាក់មួយ ហើយឲ្យពួកគេដាក់ទឹកនៅក្នុងប៉េងប៉ោង នោះ

៣. ជ្រើសរើសកុមារម្នាក់ ហើយឲ្យគេអង្គុយបែរខ្នងដាក់កុមារផ្សេងទៀត



៤. កុមារទាំងអស់និងប្តូរវេនគ្នាក្នុងការគប់ប៉េងប៉ោងទឹកនោះ ឲ្យត្រូវកុមារដែលអង្គុយលើកៅអី

៥. នៅពេលដែលប៉េងប៉ោងនោះគប់ត្រូវកុមារដែលអង្គុយនោះហើយ កុមារដែលអង្គុយនៅលើកៅអីត្រូវក្រោកឈរឡើងហើយទាយថា កុមារណាជាអ្នកគប់ប៉េងប៉ោងត្រូវគាត់នោះ។ ប្រសិនបើកុមារនោះទាយត្រូវ កុមារដែលជាអ្នកគប់ទឹកត្រូវមកអង្គុយលើកៅអីធ្វើជាអ្នកទាយវិញម្តង រួចបន្តលេងល្បែងនេះ។

**៤. ការណែនាំមេរៀន**

តើអ្នកធ្វើអ្វីដើម្បីឱ្យឪពុកម្តាយអ្នកមានមោទនភាព? តើអ្នកនឹងសម្អាតផ្ទះឬ? តើអ្នជួយកមើលថែបងប្រុសឬបងស្រីរបស់អ្នកឬ? តើអ្នកស្តាប់តាមអ្វីដែលពួកគេនិយាយទេ? ថ្ងៃនេះ យើងនឹងរៀនអំពីព្រះយេស៊ូវ ដែលធ្វើឲ្យព្រះវរបិតារបស់ទ្រង់មានមោទនភាពយ៉ាងខ្លាំង!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវមានបងប្អូនជីដូនមួយឈ្មោះ **យ៉ូហានបាទីស្ទ**។ យ៉ូហានបានធ្វើដំណើរជុំវិញជនបទ ដើម្បីប្រាប់អ្នកឯទៀតអំពីព្រះ។ ពេលមនុស្សសម្រេចចិត្តជឿលើព្រះ យ៉ូហានបានធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេ។ យ៉ូហាននឹងនាំពួកគេទៅក្នុងទន្លេយ័រដាន់ ហើយធ្វើពិធីជ្រមុជទឹកឲ្យពួកគេ។ វាជាផ្លូវមួយបង្ហាញថាពួកគេកំពុងលាងជម្រះអំពើបាបរបស់ពួកគេ ដោយចាប់ផ្តើមជីវិតថ្មី និងជឿលើព្រះ។

ថ្ងៃមួយ ព្រះយេស៊ូវយាងទៅទន្លេយ័រដាន់។ ទ្រង់បានជួបបងប្អូនជីដូនមួយរបស់គាត់គឺ យ៉ូហាននៅទីនោះ។ ព្រះយេស៊ូវបានសុំយ៉ូហានឲ្យធ្វើបុណ្យជ្រមុជទឹកដល់ទ្រង់ ប៉ុន្តែយ៉ូហានបាទីស្ទបានដឹងថា ព្រះយេស៊ូវគឺជា ព្រះរាជបុត្រានៃព្រះ ជាម្នាក់ដែលគ្មានបាបសោះ។ ដូច្នេះ យ៉ូហានបាទីស្ទបាននិយាយថា គាត់គួរតែ ទទួលបុណ្យជ្រមុជទឹកដោយព្រះយេស៊ូវជំនួសវិញ។ ប៉ុន្តែព្រះយេស៊ូវបានប្រាប់យ៉ូហានថា វាជារឿងត្រឹមត្រូវ។ ដូច្នេះព្រះយេស៊ូវ និងយ៉ូហានបានដើរទៅក្នុងទន្លេ ហើយយ៉ូហានបានជ្រមុជទឹកឲ្យ ព្រះយេស៊ូវនៅទីនោះ។

ពេលព្រះយេស៊ូវយាងចេញពីទឹក ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះពីស្ថានសួគ៌មកដូចសត្វព្រាប។ នោះក៏មានសំឡេងពីលើមេឃថា៖ “នោះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់” នេះបង្ហាញពីព្រះ ត្រីឯក - ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក ព្រះវិញ្ញាណបរិសុទ្ធបានយាងមកដូចជាសត្វព្រាប ហើយ ព្រះដែលជាព្រះវរបិតាមានបន្ទូលពីស្ថានសួគ៌មក!

នៅពេលដែលព្រះមានបន្ទូលដូច្នេះ ព្រះយេស៊ូវមិនទាន់បានធ្វើអ្វីនៅឡើយទេ! ព្រះអង្គមិនទាន់បានចាប់ផ្តើមចែកចាយព្រះបន្ទូលទេ។ ព្រះអង្គមិនបានព្យាបាលនរណាម្នាក់ទេ។ ព្រះអង្គមិនទាន់បានសុគត់នៅលើឈើឆ្កាង ឬរស់ឡើងវិញទេ។ ដូច្នេះ ហេតុអ្វីបានជាព្រះវរបិតាពេញចិត្តនឹងព្រះយេស៊ូវ? ព្រះវរបិតាសព្វព្រះហឫទ័យនឹងព្រះយេស៊ូវ ដោយសារព្រះវរបិតាបានដឹងថា ព្រះយេស៊ូវនឹងស្តាប់បង្គាប់ព្រះអង្គ។ ព្រះវរបិតាដឹងថា ព្រះយេស៊ូវនឹងបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ដល់មនុស្សគ្រប់គ្នា។ ព្រះវរបិតាបានស្រឡាញ់ព្រះយេស៊ូវ ហើយព្រះយេស៊ូវក៏ស្រឡាញ់ទ្រង់ដែរ ។ នោះជាអ្វីដែលព្រះវរបិតាសព្វព្រះទ័យ!

ព្រះសព្វព្រះទ័យនឹងយើង ពេលយើងស្រឡាញ់ព្រះអង្គ! ព្រះអង្គពេញចិត្តនៅពេលយើងធ្វើអ្វីដែលទ្រង់ចង់បាន ប៉ុន្តែព្រះដឹងថាយើងមិនអាចល្អឥតខ្ចោះ ហើយទ្រង់ក៏មិនរំពឹងថាយើងនឹងល្អឥតខ្ចោះដែរ។ ហេតុនេះ ហើយបានជាព្រះបានចាត់ព្រះយេស៊ូវជាបុត្រដ៏ល្អឥតខ្ចោះរបស់ទ្រង់មកឯយើង។ នៅពេលដែលយើងជឿ លើព្រះយេស៊ូវ និងអ្វីដែលទ្រង់បានធ្វើសម្រាប់យើងនៅលើឈើឆ្កាង នោះព្រះទ្រង់ទតឃើញ ព្រះយេស៊ូវ នៅពេលដែលទ្រង់សម្លឹងមកយើង! ហើយនោះធ្វើឱ្យព្រះមើលឃើញយើងល្អឥតខ្ចោះ។ ហេតុនេះហើយ បានជាយើងថ្វាយបង្គំព្រះយេស៊ូវ ជាព្រះរាជបុត្រារបស់ព្រះ!

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាយ៉ូហានបាទីស្ទធ្វើដំណើរជុំវិញជនបទ? *(ប្រាប់មនុស្សអំពីព្រះ)*

២. តើយ៉ូហានបាទីស្ទបានធ្វើអ្វីសំរាប់មនុស្សដែលមកជឿលើព្រះ?
*(គាត់បានធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេនៅទន្លេយ័រដាន់)*

៣. ហេតុអ្វីបានជាយ៉ូហានបាទីស្ទព្យាយាមរារាំងព្រះយេស៊ូវមិនឲ្យទទួលការជ្រមុជទឹកពីគាត់?
*(ដោយសារគាត់បានដឹងថាព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះដែលគ្មានបាប)*

៤. តើព្រះយេស៊ូវជានរណា ហើយហេតុអ្វីយើងថ្វាយបង្គំទ្រង់? *(ទ្រង់ជាព្រះរាជបុត្រានៃព្រះ)*

**៧. ល្បែងកំសាន្ត** **«បូមទឹកដាក់ដប»**

សម្ភារៈដែលត្រូវការ៖ ធុងទឹកធំ២ ស្លឹកចេកឬក៏ស្លឹកឈូក ដបទឹកសុទ្ធ១,៥លីត្រ ២ដប



១. ដាក់ទឹកឲ្យពេញក្នុងធុងធំៗទាំង២នោះ ហើយដាក់វានៅចុងថ្នាក់រៀន

២. ចែកកុមារជា២ក្រុម ហើយឲ្យដបទឹកសុទ្ធ១,៥លីត្រ ឲ្យទៅក្រុមនីមួយៗ

៣. ឲ្យស្លឹកចេកឬក៏ស្លឹកឈូកទៅកុមារគ្រប់គ្នាៗ ហើយឲ្យពួកគេព្យាយាមបត់ស្លឹកនោះឲ្យក្លាយជាកន្ទោង ឬ ជាអ្វីក៏បានដែលគេអាចដួសទឹកបាន



៤. កុមារទាំងអស់ត្រូវប្តូរវេនគ្នារត់ទៅដួសទឹកនៅក្នុងធុងធំនោះ ហើយរត់យកវាមកដាក់ចូលក្នុងដបទឹកសុទ្ធទទេ ដែលនៅចុងម្ខាងទៀតនៃថ្នាក់រៀន។ ក្រុមណាដែលអាចយកទឹកមកដាក់ពេញដបមុនក្រុមនោះជា អ្នកឈ្នះ។

**៨. ខគម្ពីរចងចាំ**

**ម៉ាថាយ ៣៖១៧** *“នោះមានឮសំឡេងចេញពីមេឃថា នោះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់។”*

**៩. ហាត្ថកម្ម** ផាត់ពណ៌ **«ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក»**

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវគឺអស្ចារ្យណាស់។ យើងគួរដឹងគុណដល់ព្រះរាជបុត្រានៃព្រះជារៀងរាល់ថ្ងៃ—សម្រាប់ការបង្ហាញផ្លូវដល់យើងទៅរកព្រះ និងភាពស្រស់ស្អាតនៃជីវិតរស់នៅសម្រាប់ទ្រង់។ ក្នុងជីវិតរបស់ទ្រង់ នៅលើផែនដីនេះ ព្រះយេស៊ូវបានណែនាំមនុស្សឲ្យស្គាល់ព្រះ។ បន្ទាប់ពីព្រះយេស៊ូវបានឡើងទៅស្ថានសួគ៌ ពួកសិស្សរបស់ទ្រង់បានធ្វើតាមគំរូរបស់ព្រះអង្គ ហើយនាំអ្នកឯទៀតឲ្យជឿលើព្រះ និងការលះបង់របស់ព្រះយេស៊ូវ។ យើងគួរធ្វើតាមគំរូដូចគ្នាដើម្បីដឹកនាំអ្នកដទៃឲ្យមានជំនឿដូចគ្នា។ តើអ្នកអាចធ្វើអ្វីខ្លះនៅថ្ងៃនេះ ដើម្បីជួយអ្នកដទៃឲ្យជឿលើព្រះយេស៊ូវ?

# ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________

______________________________

______________________________

______________________________